**STATE OF ILLINOIS**
**DEPARTMENT OF HUMAN SERVICES**
**DIVISION OF REHABILITATION SERVICES**

# រដ្ឋអ៊ីលីណយស៍
# ក្រសួងសេវាកម្មមនុស្សជាតិ
# ផ្នែកសេវាកម្មស្តារនិតិសម្បទា
# សន្លឹកព័ត៌មាន
# ការទទួលបាននូវសេវាកម្មស្តារនិតិសម្បទាខាងវិជ្ជាជីវៈសម្រាប់ជនពិការ

ផ្នែកសេវាកម្មស្តារនិតិសម្បទា (DRS) គឺជាកម្មវិធីមួយរបស់រដ្ឋ និង សហព័ន្ធ ដែលមានទិសដៅជាចម្បង ផ្តល់នូវសេវាកម្មស្តារនិតិសម្បទាខាងវិជ្ជាជីវៈ (VR) និងការងារដល់ជនពិការគ្រប់ជាតិសាសន៍ និង សាវតារទាំងអស់ ។ DRSគឺជាផ្នែកមួយនៃក្រសួងសេវាកម្មមនុស្សជាតិ (DHS) នៅក្នុងរដ្ឋអ៊ីលីណយស៍។

DRS ប្តេជ្ញាចិត្តជួយទ្រទ្រង់ជនពិការក្នុងការត្រៀមខ្លួន ការពារ រក្សា ឬទទួលបានមកវិញនូវការងារក្នុងសហគមន៍របស់ពួកគេ។ ដោយសារជនពិការ -ជាពិសេសក្រុមជនជាតិភាគតិច ជនអន្តោប្រវេសន៍ និង ជនភៀសខ្លួន ដែលមានពិការភាព- ទទួល សេវាកម្ម ដែល DRS ផ្តល់ឱ្យមិនបានគ្រប់គ្រាន់ ទើបប្រព័ន្ធ VR នៅរដ្ឋអ៊ីលីណយស៍ កំពុងតែឈោងដៃទៅជួយសហគមន៍ចម្រុះទាំងអស់នេះ។

ដោយមានការឧបត្ថម្ភគាំទ្រនិងការបណ្តុះបណ្តាលត្រឹមត្រូវ ជនពិការនៅរដ្ឋអ៊ីលីណយស៍អាចទទួលបាននូវមុខរបរនិងឱកាសការងារគួរជាទីពេញចិត្ត ។ តទៅនេះគឺជាចម្លើយចំពោះសំណួរដែលគេសួរជាញឹកញាប់អំពីសេវាកម្មដែលអាចរកបាន ។ ចូរអាននូវសេចក្តីទាំងនេះដើម្បីឱ្យដឹងថាតើអ្នកឬជនដែលអ្នកស្គាល់មានលទ្ធភាពទទួលបានឬទេ។

## ? សំណួរដែលគេសួរជាញឹកញាប់ ?

១. **តើអ្វីទៅដែលហៅថា "ជនពិការ"?** ជនពិការគឺជាមនុស្សដែលមានរាងកាយឬសតិស្មារតី មិនគ្រប់លក្ខណៈដែលធ្វើឱ្យមានការលំបាកដល់បុគ្គលនោះក្នុងការបំពេញការងារ ។ ឧទាហរណ៍ មនុស្សម្នាក់អាចនឹងមានពិការភាពប្រសិនបើគាត់:

- ថ្លង់ ឬមានបញ្ហាលំបាកធ្ងន់ធ្ងរចំពោះការស្តាប់ឮ
- ងងឹតភ្នែក ឬមានបញ្ហាលំបាកធ្ងន់ធ្ងរចំពោះការមើលឃើញ សូម្បីតែពេលកំពុងពាក់វ៉ែនតា
- មានបញ្ហាលំបាកធ្ងន់ធ្ងរចំពោះការប្រមូលអារម្មណ៍ ការចងចាំ ឬការធ្វើសេចក្តីសម្រេចចិត្ត
- មានបញ្ហាលំបាកចំពោះការស្លៀកពាក់ ឬងូតទឹក
- មានបញ្ហាលំបាកចំពោះការធ្វើការងារប្រចាំថ្ងៃតែឯង ដូចជាការទៅជួបគ្រូពេទ្យ ឬការទិញឥវ៉ាន់
- មានបញ្ហាលំបាកក្នុងការផ្លាស់ទីពីកន្លែងមួយទៅកន្លែងមួយ ឬធ្វើចលនារាងកាយរបស់ខ្លួនក្នុងឥរិយាបថណាមួយ (ឧទាហរណ៍ ការដើរ គោងឡើង លុតជង្គង់ អង្គុយ និង ឈរ)
- មានបញ្ហាលំបាកធ្ងន់ធ្ងរចំពោះការសម្តែងអាកប្បកិរិយាសមរម្យនិងគួរសមនៅកន្លែងធ្វើការ។

២. **តើខ្ញុំ (ឬជនដែលខ្ញុំស្គាល់) មានលទ្ធភាពទទួលបានសេវាកម្ម VR ដែរឬទេ?** វាគឺជាការងាររបស់បុគ្គលិកជំនាញ VR ក្នុងការសម្រេចថាតើអ្នកឬជនដែលអ្នកស្គាល់នោះមានពិការភាពឬអត់ហើយ មានលទ្ធភាពទទួលបានសេវាកម្មពី ផ្នែក DRS ឬទេ ដើម្បីជួយរកការងារឱ្យអ្នកធ្វើ ឬរក្សាការងាររបស់អ្នកបានគង់វង្ស ។ ជនដែលដាក់ពាក្យសុំនេះគួរមានច្បាប់អនុញ្ញាតត្រឹមត្រូវដើម្បី ធ្វើការនៅក្នុងសហរដ្ឋអាមេរិក និងនៅក្នុងដែនដីនានារបស់អាមេរិក។

៣. **តើសេវាកម្មអ្វីខ្លះដែល DRS-VR អាចផ្តល់ឱ្យខ្ញុំបាន?** DRS ផ្តល់នូវសេវាកម្មជាច្រើនដែលមានសារៈប្រយោជន៍ចំពោះ ការហ្វឹកហ្វឺន ការងារ ការសិក្សាអប់រំ និង/ឬ តម្រូវការផ្នែកការងាររបស់អ្នក ។ កិច្ចគាំទ្រទាំងនេះរួមមាន : ការប្រឹក្សា និង ការណែនាំផ្នែកវិជ្ជាជីវៈ ការបញ្ជូនទៅកាន់អ្នកផ្តល់ជំនួយសហគមន៍ដែលស័ក្តិសម ការហ្វឹកហ្វឺនជំនាញការងារ និងការរកការងារឱ្យធ្វើ កិច្ចទ្រទ្រង់ការងាររយៈពេលវែង (ឧ. មានអ្នកជួយថែទាំសុខភាពផ្ទាល់ខ្លួន ឬ អ្នកជួយហ្វឹកហ្វឺនការងារ) ការប្រើប្រាស់បច្ចេកវិទ្យាជាជំនួយ ឬ ជំនួយដែលពាក់ព័ន្ធ និង ការទទួលបានសេវាកម្មបណ្តោះអាសន្ន និង ជម្រើសហ្វឹកហ្វឺននៅមហាវិទ្យាល័យ។

៤. **តើខ្ញុំត្រូវដាក់ពាក្យសុំយ៉ាងដូចម្តេច?** អ្នកអាចដាក់ពាក្យសុំសេវាកម្ម VR នេះ តាមប្រព័ន្ធអ៊ីនធឺណិត តាមទូរស័ព្ទ តាមទូរសារ (fax) ឬ ទៅកាន់ការិយាល័យក្នុងមូលដ្ឋានរបស់អ្នក ។ អ្នកអាចដាក់ពាក្យសុំតាមប្រព័ន្ធអ៊ីនធឺណិត តាមអាស័យដ្ឋាន drs.illinois.gov/apply ។ ម្យ៉ាងទៀត អ្នកអាចទាក់ទងទៅការិយាល័យ DRS ក្នុងមូលដ្ឋានរបស់អ្នក ដែលស្ថិតនៅជិតផ្ទះអ្នកជាងគេ តាមរយៈលេខ (800-843-6154) *(ភាសាអង់គ្លេស ឬ អេស្ប៉ាញ)* ឬ ទាក់ទងទៅទីភ្នាក់ងារ សហគមន៍ពហុវប្បធម៌ដែលមានចុះក្នុងបញ្ជីសម្រាប់ជំនួយភាសាដើម្បីជួយអ្នកតភ្ជាប់ទំនាក់ទំនងទៅDRS ។ សម្រាប់ពត៌មានបន្ថែមស្តីពីសេវាកម្មដែល DRS ផ្តល់ឱ្យ សូមទៅកាន់ drs.illinois.gov ។

៥. **តើខ្ញុំត្រូវបង់ថ្លៃសម្រាប់សេវាកម្ម VR ដែរឬទេ?** សេវាកម្មមួយចំនួន ដែល DRS ផ្តល់ឱ្យ គឺយោងទៅលើប្រាក់ចំណូលរបស់អ្នក ។ បើត្រូវបង់ថ្លៃខ្លះ អ្នកផ្តល់ឱវាទរបស់អ្នកនឹងពិគ្រោះនិងពន្យល់ប្រាប់អំពីតម្លៃនោះដល់អ្នក ។ សេវាកម្មជាច្រើនឥតមានគិតថ្លៃទេ ។

៦. **តើត្រូវធ្វើដូចម្តេច ប្រសិនបើខ្ញុំមិនចេះនិយាយភាសាអង់គ្លេស?** ប្រសិនបើអ្នកត្រូវការជំនួយផ្នែកភាសា សូមប្រាប់ទៅអ្នកផ្តល់ឱវាទ VR របស់អ្នក ដើម្បីឱ្យគាត់អាចជួយសម្រួលនូវតម្រូវការខាងភាសានិងវប្បធម៌របស់អ្នក ។

**ស្តាប់នៅគួរឱ្យចាប់អារម្មណ៍មែន ៗ តើខ្ញុំត្រូវចាប់ផ្តើមយ៉ាងដូចម្តេច?**

នៅពេលអ្នកជួបជាមួយអ្នកផ្តល់យោបល់VR របស់អ្នកនៅលើកទីមួយ សូមយកឯកសារឱ្យបានច្រើន មកជាមួយអ្នក ដែលមានរាយ ឈ្មោះដូចតទៅនេះ៖

**<u>អ្នកដាក់ពាក្យសុំទាំងអស់</u>**

- ✓ ប័ណ្ណពេទ្យMedicaid និង/ឬMedicare
- ✓ លិខិតទទួលរង្វាន់សន្តិសុខសង្គម(Social Security Award Letter)
- ✓ បញ្ជីការងារពីអតីត និង សញ្ញាប័ត្រ ឬវិញ្ញាបនប័ត្រដែលអ្នកបានទទួល
- ✓ រាល់ពត៌មានផ្នែកពេទ្យបច្ចុប្បន្នដែលអាចរកបានស្តីពីជំងឺរបស់អ្នក ។ ពត៌មាននេះគឺជាលិខិតសរសេរជាអក្សរពុម្ព ឬសរសេរដោយដៃ អាចមើលដាច់ ចេញដោយវេជ្ជបណ្ឌិត

អ្នកព្យាបាលរោគដែលមានសញ្ញាប័ត្រ ឬ អ្នកចិត្តសាស្ត្រ ស្តីពី:

- រោគវិនិច្ឆ័យ/បុរេនិមិត្ត
- រោគសញ្ញា រួមមានផលប៉ះពាល់ ឬ ប្រតិកម្មអាក្រក់ពីថ្នាំពេទ្យ
- គម្រោងព្យាបាល ដោយរាប់ទាំង បញ្ជីថ្នាំពេទ្យ ។
- លិខិតបញ្ជាក់យល់ព្រមឱ្យធ្វើការងារ មានរួមទាំង ការកំហិត ឬ ការសម្រុះសម្រួលនានា
- ឈ្មោះ អាស័យដ្ឋាន និង លេខទូរស័ព្ទរបស់វេជ្ជបណ្ឌិតដែលចេញលិខិតនេះ

**បញ្ជីឈ្មោះនៃអង្គការពហុវប្បធម៌ Listing of Multicultural Organizations**

| ឈ្មោះអង្គការ | ព័ត៌មានលម្អិតអំពីមនុស្ស ដែលត្រូវទំនាក់ទំនង | ជំនាញភាសា |
|---|---|---|
| **សេវាកម្មគ្រួសារជនជាតិ អាមេរិកាំងដើមកំណើតអារ៉ាប់**<br>**Arab American Family Services**<br>9044 S Octavia Ave, Bridgeview, IL 60455<br>ទូរស័ព្ទ[3] (708) 599-2237 ហ្វាក់ស៍: (708) 599-8299<br>វ៉ែបសៃ: www.arabamericanfamilyservices.org | Itedal Shalabi, Executive Director<br>នាយកប្រតិបត្តិ<br>អ៊ីម៉ែល: itedals@yahoo.com<br>ទូរស័ព្ទ[3] (708) 599-2237 លេខបន្ត. 31 | ភាសា អារ៉ាប់ |
| **សេវាកម្មមនុស្សធម៌អាស៊ី**<br>**Asian Human Services**<br>4753 N Broadway St, Suite 700, Chicago, IL 60640<br>ទូរស័ព្ទ: (773) 728-2235 ហ្វាក់ស៍: (773) 561-1396<br>វ៉ែបសៃ: www.ahschicago.org | Jing Zhang, Director of Community Health Programs នាយកផ្នែកកម្មវិធីសុខភាព សហគមន៍<br>អ៊ីម៉ែល: jzhang@ahschicago.org<br>ទូរស័ព្ទ: (773) 293-8460 | មានជាង ២៨ ភាសា (ឧ.: ភាសាចិន, ហិណ្ឌី, ហ្មុង, ខ្មែរ, ឡាវ, ថៃ & អូឌូ) |
| **សមាគមខ្មែរ រដ្ឋ អ៊ីល្លីណយស៍**<br>**Cambodian Association of Illinois**<br>2831 W Lawrence Ave, Chicago, IL 60625<br>ទូរស័ព្ទ: (773) 878-7090 ហ្វាក់ស៍: (773) 878-5299<br>វ៉ែបសៃ: www.cai.maaillinois.org | Kathy Reun, Immigration & Family Resources Coordinator អ្នកសម្របសម្រួលផ្នែក ធនធាន គ្រួសារ និង អន្តោប្រវេសន៍<br>អ៊ីម៉ែល: kathy@cambodian-association.org<br>ទូរស័ព្ទ: (773) 878-7090 លេខបន្ត. 205 | ភាសាខ្មែរ |
| **សម្ព័ន្ធអង្គការចិនអាមេរិកាំង**<br>**Chinese American Service League (CASL)**<br>2141 S Tan Court, Chicago, IL 60616<br>ទូរស័ព្ទ: (312) 791-0418 ហ្វាក់ស៍: (312) 791-0509<br>វ៉ែបសៃ: www.caslservice.org | Ivy Siu, Family & Community Services Department Manager អ្នកចាត់ចែងផ្នែកសេវាកម្ម សហគមន៍ និង គ្រួសារ<br>អ៊ីម៉ែល: ivy_siu@caslservice.org<br>ទូរស័ព្ទ: (312) 791-0418 លេខបន្ត. 2202 | ភាសា ចិន_ខេនថូនីស៍ និង ម៉ែនដារិន |
| **សមាគម ជំនួយទៅវិញទៅមក ជនជាតិចិន**<br>**Chinese Mutual Aid Association**<br>1016 W Argyle St, Chicago, IL 60640<br>ទូរស័ព្ទ: (773) 784-2900 ហ្វាក់ស៍: (773) 784-2984<br>វ៉ែបសៃ: www.chinesemutualaid.org | Jamie Taradash, Rehabilitation Services Project Developer<br>អ្នកបណ្តុះបណ្តាលផ្នែក កិច្ចការ សេវាកម្មស្តារនីតិសម្បទា<br>អ៊ីម៉ែល: jamiet@chinesemutualaid.org<br>ទូរស័ព្ទ: (773) 784-2900 លេខបន្ត. 110 | មានជាង ២៨ ភាសា (ឧ.: ភាសា បូស្នៀ, ភូមា ចិន_ខេនថូនីស៍/ ម៉ែនដារិន នេប៉ាល់&វៀតណាម |
| **មជ្ឈមណ្ឌល ឥណ្ឌូ អាមេរិកាំង**<br>**Indo-American Center**<br>6328 N California Ave, Chicago, IL 60659<br>ទូរស័ព្ទ: (773) 973-4444 ហ្វាក់ស៍: (773) 973-0157<br>វ៉ែបសៃ: www.indoamerican.org | Sunitha Doma, Public Benefits Coordinator អ្នកសម្របសម្រួលផ្នែកប្រាក់កម្រៃ សាធារណៈ<br>អ៊ីម៉ែល: sdoma@indoamerican.org<br>ទូរស័ព្ទ: (773) 973-4444 លេខបន្ត. 109 | ភាសា បេងហ្កាលី ហ្គូចារ៉ាទី ហិណ្ឌី ពុនចាប៊ី និង អូឌូ |
| **សេវាកម្មសហគមន៍ កូរ៉េ អាមេរិកាំង**<br>**Korean American Community Services**<br>4300 N California Ave, Chicago, IL 60618<br>ទូរស័ព្ទ: (773) 583-5501 ហ្វាក់ស៍: (773) 583-7009<br>វ៉ែបសៃ: www.kacschicago.org | Mi Young Seo, Director of Senior Services & Public Benefits<br>នាយកផ្នែកសេវាកម្មមនុស្សចាស់ជរា និង ប្រាក់កម្រៃសាធារណៈ<br>អ៊ីម៉ែល: mseo@kacschicago.org<br>ទូរស័ព្ទ: (773) 583-5501 លេខបន្ត. 160 | ភាសា កូរ៉េ និង អេស្ប៉ាញ |
| **សេវាកម្ម សហគមន៍ ឡាវ អាមេរិកាំង**<br>**Lao American Community Services**<br>4750 N Sheridan Rd. Suite 369, Chicago, IL 60640<br>ទូរស័ព្ទ: (773) 271-0004 ហ្វាក់ស៍: (773) 271-1682<br>វ៉ែបសៃ: www.lacschicago.org | Thavone Nyatso, Executive Director<br>នាយកប្រតិបត្តិ<br>អ៊ីម៉ែល: info@lacschicago.org<br>ទូរស័ព្ទ: (773) 271-0004 | ភាសា ឡាវ និង ថៃ |

| | | |
|---|---|---|
| **មជ្ឈមណ្ឌល ធនធាន ស្ត្រី មូស្លីម**<br>**Muslim Women Resource Center**<br>6445 N Western Ave, #301, Chicago, IL 60659<br>ទូរស័ព្ទ: (773) 764-1686 ហ្វាក់ស៍: (773) 764-6753<br>វេបសៃ: www.mwrcnfp.org | Sima Quraishi, Executive Director<br>នាយកប្រតិបត្តិ<br>អ៊ីម៉ែល: sima@mwrcnfp.org<br>ទូរស័ព្ទ: (773) 764-1686 | ភាសា អួឌូ |
| **មជ្ឈមណ្ឌល នេប៉ាល់ អាមេរិកាំង**<br>**Nepali American Center**<br>6 E Jerry St, Mount Prospect, IL 60056<br>ទូរស័ព្ទ: (773) 800-1622<br>វេបសៃ: www.nepaliamericancenter.org | Ankur Sharma, General Secretary<br>អគ្គលេខាធិការ<br>អ៊ីម៉ែល: info@nepaliamericancenter.org<br>ទូរស័ព្ទ: (773) 800-1622 | ភាសា នេប៉ាល់ & ភាសា កុលសម្ព័ន្ធ ផ្សេងៗទៀតនៃប្រទេសនេប៉ាល់ |
| **អង្គការ សហភាព អាហ្វ្រិក**<br>**United African Organization**<br>3424 S State St, Suite 3C8-2, Chicago, IL 60616<br>ទូរស័ព្ទ: (312) 949-9980 ហ្វាក់ស៍: (312) 949-9981<br>វេបសៃ: www.uniteafricans.org | Nancy Asirifi-Otchere, Program Coordinator អ្នកសម្របសម្រួលកម្មវិធី<br>អ៊ីម៉ែល: Nancy.asirifi-otchere@uniteafricans.org<br>ទូរស័ព្ទ: (312) 949-9980 | ភាសា បារាំង, សូម៉ាលី, & ភាសា អាហ្វ្រិកធំៗទាំងអស់ |
| **សមាគម វៀតណាម រដ្ឋ អ៊ីល្លីណយស៍**<br>**Vietnamese Association of Illinois**<br>5110 N Broadway St, 2nd Floor, Chicago, IL 60640<br>ទូរស័ព្ទ: (773) 728-3700 ហ្វាក់ស៍: (773) 728-0497<br>វេបសៃ: www.hnvi.org | Van Duong, Healthcare & Community Program Manager អ្នកចាត់ចែងកម្មវិធីសហគមន៍ និង ការថែទាំសុខភាព<br>អ៊ីម៉ែល: vlduong@yahoo.com<br>ទូរស័ព្ទ: (773) 728-3700 | ភាសា វៀតណាម |